រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

004KH01A-01

ស្តេចដាវីឌ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៤

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ប្រទានសេចក្តីក្លាហានដល់អ្នក នៅពេលដែលអ្នកសិក្សាមេរៀននេះ ។



កិច្ចការដែលត្រូវអនុវត្ត

- អាន ១ សាមូអែល ជំពូក ១៦ និង ១៧ ។
- អធិស្ឋាន និង រិះគិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ហើយពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធគ្រប់ពេល ។
- បង្រៀនក្រុមជំនុំរបស់អ្នកអំពីគំរូរបស់ស្តេចដាវីឌ ដើម្បីអោយពួកគេអធិស្ឋាន រិះគិតពិចារណាពីព្រះបន្ទូល និងជីវិតឡើងខាងជំនឿ ព្រមទាំងសេចក្តីក្លាហាន ដោយពឹងលើព្រះវិញ្ញាណដ៏វិសុទ្ធ ។
- អានទំនុកតម្កើង ១១៩ ។ ទំនុកតម្កើងនេះបង្ហាញពីសេចក្តីស្រឡាញ់ដ៏ធំ ដែលយើងត្រូវមានចំពោះព្រះបន្ទូលរបស់-ព្រះជាម្ចាស់ ។
- ខិតខំឱ្យបានផ្សព្វផ្សាយដំណឹងល្អ ទៅអ្នកណាម្នាក់រាល់ថ្ងៃ ។

© Project WorldReach © SEAN

៤- ដាវីឌមានសេចក្តីក្លាហាន ពីព្រោះគាត់មិនដែលនៅតែម្នាក់ឯងទេ ។ តើអ្នកណាដែលនៅជាប់ជាមួយគាត់ ?

☐ ឪពុកគាត់ឈ្មោះយេសាយ ។

☐ ព្រះវិញ្ញាណដ៏វិសុទ្ធ ។

៥- យើងពឹងលើព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីអាច :

☐ ផ្សព្វផ្សាយដំណឹងល្អ ។

☐ ទិតៀនកំហុសរបស់អ្នកដទៃ ។

កំណត់ចំណាំ :

កាលពីបីពាន់ឆ្នាំមុន...



ដាវីឌជាអ្នកគង្វាលចៀមសាមញ្ញម្នាក់ ។ គាត់រស់នៅក្បែរភ្នំនៅភូមិបេថ្លេហិម ។ ក្រោមការដឹកនាំរបស់យ៉ូស្វ៉ូអា ពួកអ៊ីស្រាអែលបានកាន់កាប់ទឹកដីសន្យា ។ ស្តេចសូលជាស្តេចទី១របស់ពួកគេ តែស្តេចសូល មិនបានប្រតិបត្តិតាមព្រះអម្ចាស់ទេ ។ ដូច្នេះ ក្នុងពេលនោះ ព្រះជាម្ចាស់រៀបចំដាវីឌ ដើម្បីគ្រប់គ្រងប្រជារាស្ត្ររបស់ព្រះអង្គវិញ ។

© Project WorldReach © SEAN

ដាវីឌចេះលេងពិណ និងចេះនិពន្ធបទចំរៀងសរសើរតម្កើង ។ ចំរៀងទាំងនោះ បង្ហាញពីសេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះ-បន្ទូលព្រះជាម្ចាស់ ។ ព្រះជាម្ចាស់ពង្រឹងដាវីឌអោយមានជំនឿ និងចិត្តក្លាហាន ដោយសារតែគាត់មានភក្តីភាពយ៉ាងខ្លាំងចំពោះទ្រង់ ។ នៅពេលដែលសត្វតោមួយ និងសត្វខ្លាឃ្មុំមួយមកវាយប្រហារហ្វូងចៀម ដាវីឌបានសម្លាប់សត្វទាំងនោះ ។



ថ្ងៃមួយ ព្យាការីសាមូអែលបានចាក់ប្រេងអភិសេក ដើម្បីឱ្យដាវីឌក្លាយជាស្តេច ។ ចាប់តាំងពីពេលនោះមក ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់យាងមកសណ្ឋិតលើដាវីឌ ហើយដឹកនាំដាវីឌអោយទៅតាមមាគ៌ាពិសេសមួយ (១ សាមូអែល ១៦:១៣) ។

«ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះបន្ទូលដ៏មានជីវិត និងមានមហិទ្ធិឫទ្ធិ មុតជាងដាវមុខពីរទៅទៀត ។ ព្រះបន្ទូលនេះចាក់ទម្លុះចូលទៅកាត់ព្រលឹង និងវិញ្ញាណដាច់ចេញពីគ្នា កាត់សន្លាក់ឆ្អឹង និងខួរឆ្អឹងចេញពីគ្នា ។ ព្រះបន្ទូលវិនិច្ឆ័យឆន្ទៈ និងគំនិតនៅក្នុងជំរៅចិត្តមនុស្ស» ។ (ហេប្រឺ ៤:១២)

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- ដាវីឌអានព្រះបន្ទូលព្រះជាម្ចាស់ ដោយ :

☐ សេចក្តីស្រឡាញ់ ។

☐ មានគំនិតចង់ដឹង ។

២- ដោយសារតែដាវីឌ ស្រឡាញ់ព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងខ្លាំង ទើបដាវីឌមានទម្លាប់ :

☐ សូត្រព្រះបន្ទូល ។

☐ រិះគិតពិចារណាពីព្រះបន្ទូល ។

៣- ដាវីឌចាំព្រះបន្ទូលក្នុងចិត្ត ដោយសារតែដាវីឌឧស្សាហ៍រិះគិតពិចារណាអំពីព្រះបន្ទូលយ៉ាងខ្លាំង ។ កំណប់នេះ ធ្វើអោយដាវីឌមានជំនឿ និង :

☐ ទ្រព្យសម្បត្តិ ។

☐ សេចក្តីក្លាហាន ។

© Project WorldReach © SEAN



ពេលនោះ ប្រទេសអ៊ីស្រាអែលមានសង្គ្រាមជាមួយពួកភីលីស្ទីន។ ពួកបងប្រុសរបស់ដាវីឌចូលបំរើក្នុងកងទ័ពអ៊ីស្រាអែល ។

ថ្ងៃមួយ យេសាយជាឪពុករបស់ដាវីឌ ប្រាប់ដាវីឌថា÷...



ពេលដាវីឌទៅដល់ទីលានប្រយុទ្ធ ដាវីឌបានឮពាក្យជេរប្រទេច
របស់កូលីយ៉ាត ។ កូលីយ៉ាតជាមនុស្សមានឌធំដូចយក្ស កំពស់
ប្រមាណបីម៉ែត្រ ។



ចូរចាប់ផ្តើមពីពេលនេះទៅ ដោយធ្វើកិច្ចការតូចតាចសិន
ណាឬអ្នក គឺផ្សព្វផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត ប្រាប់ទៅ
មិត្តភក្តិ និងសាច់ញាតិឬអ្នកទៅ ។ សូមរស់នៅដើម្បី
ព្រះគ្រីស្តចុះ ។



© Project WorldReach © SEAN



ក្ងលីយ៉ាតចេះតែបន្តស្រែកគំរាមសំឡុតទៀត ។



ដាវីឌភ្ញាក់ជាខ្លាំង ព្រោះមិនឃើញ
ជនជាតិអ៊ីស្រាអែលណាម្នាក់ចេញ
មកប្រកួតជាមួយក្ងលីយ៉ាតសោះ ។
គ្មាននរណាម្នាក់ហ៊ានការពារកិត្តិយស
របស់ព្រះរបស់ពួកអ៊ីស្រាអែលសោះ ។





ដាវីឌបានទុកចិត្តលើព្រះជាម្ចាស់
ដោយនឹកគិតដល់ព្រះបន្ទូល
របស់ព្រះអង្គ នៅក្នុងទុតិយកថា
២៨:៧ ដែលព្រះជាម្ចាស់សន្យា
ថា នឹងវាយកំចាត់សត្រូវ
ដែលមកឈ្លានពានទឹកដីបរិសុទ្ធ ។

ដាវីឌដឹងថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គង់សណ្ឋិតក្នុងខ្លួនគាត់
ដើម្បីជួយគាត់ ។ គាត់ក៏នឹកចាំពីពេលដែលព្រះជាម្ចាស់ជួយគាត់
អោយអាចសម្លាប់សត្វតោ និងសត្វខ្លាឃ្មុំបានដែរ ។



ប្រហែលជាជនជាតិភីលីស្ទីននេះអាចសំលាប់ខ្ញុំបាន
ប៉ុន្តែ បើព្រះជាម្ចាស់ចង់កំចាត់វា នោះព្រះអង្គនឹងជួយខ្ញុំ ។

ដាវីឌមានបញ្ហាច្រើនយ៉ាងណាស់ហ្ន៎ !
ធ្វើកិច្ចការថ្វាយព្រះជាម្ចាស់ ពិបាកណាស់ !



បើអញ្ចឹង ! ចាប់ផ្តើមធ្វើកិច្ចការស្រួលៗសិនទៅ គឺ
ផ្សព្វផ្សាយដំណឹងល្អ ដើម្បីនាំគ្រួសារប្អូន និងមិត្តភក្តិ
ប្អូនអោយជឿលើព្រះអង្គទៅ ។



សូមនឹកចាំពីគំរូដាវីឌ គឺអធិស្ឋាន
និងរិះគិតពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។
បើសិនជាយើងទុកចិត្តលើព្រះបន្ទូល
ព្រះជាម្ចាស់ នោះព្រះអង្គនឹងប្រទាន
កំឡាំងអោយយើង ។

© Project WorldReach © SEAN

គេទៅទូលស្តេចសូលថា : ដាវីឌចង់ទៅប្រកួតជាមួយកូលីយ៉ាត!
ស្តេចសូលក៏អោយមួកដែក និងអាវក្រោះរបស់ទ្រង់ទៅដាវីឌ ។



អាវក្រោះនេះធ្ងន់ពេក ហើយខ្ញុំមិនដែលចេះប្រើដាវទាំងនេះទេ ។ ខ្ញុំប្រើដំបង និងខ្សែដង្កត់របស់ខ្ញុំ រួចទុកចិត្តលើព្រះជាម្ចាស់វិញ ។

ដាវីឌរើសដុំក្រួសខ្លះដាក់ក្នុងថង់យាម ។
រួចយកក្រួសមួយដុំដាក់ក្នុងខ្សែដង្កត់
ហើយដើរទៅរកកូលីយ៉ាត ។



មែន ! ដាវីឌចង់តែធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ដោយសារតែគាត់រិះគិតអំពីព្រះបន្ទូលទាំងយប់ ទាំងថៃ ហើយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ក៏ជីកនាំគាត់ដែរ ។ ក្រោយមក ពេលដែលដាវីឌក្លាយជាស្តេច ទ្រង់មានទុក្ខលំបាកច្រើន តែដាវីឌនៅតែទុកចិត្តលើព្រះជាម្ចាស់ និងព្រះបន្ទូលរបស់ព្រះអង្គជានិច្ច ។ មានម្តងនោះ ដាវីឌប្រព្រឹត្តអំពើបាបមួយធ្ងន់ធ្ងរណាស់។ ប៉ុន្តែ ដោយសារតែដាវីឌទុកចិត្តលើព្រះជាម្ចាស់ ទើបទ្រង់ចេះបន្ទាបខ្លួន គឺដាវីឌអធិស្ឋាន លន់តួសារភាពកំហុសរបស់ទ្រង់ ដូច្នេះ ព្រះជាម្ចាស់ក៏លើកដាវីឌឡើងវិញ ។



ហ៎ា ហ៎ា តើយើងជាឆ្កែឬ បានជាឯងចូលមករកយើង ដោយកាន់ដំបងនោះ ?



ឯងចូលមកប្រយុទ្ធជាមួយខ្ញុំ ដោយប្រើដាវ និងលំពែង។ រីឯខ្ញុំវិញ ខ្ញុំមកវាយឯង ដោយព្រះនាមរបស់ព្រះអម្ចាស់នៃពិភពលោកទាំងមូល ជាព្រះរបស់ពួកអ៊ីស្រាអែលដែលឯងមកប្រកួតជាមួយនោះ ។

ដាវីឌទុកអោយព្រះជាម្ចាស់រៀបចំគាត់ ។ គាត់ចេះធ្វើកិច្ចការតូចតាច ដោយត្រឹមត្រូវល្អ ហើយគាត់បានបំពេញភារៈកិច្ចគាត់ជាអ្នកគង្វាលចៀមម្នាក់ ដោយជំនឿ និងដោយឧស្សាហ៍ព្យាយាម ។ គាត់បានទទួលព្រះចេស្តារបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ហើយនៅពេលដែលមនុស្សមានធំដូចយក្សមកដល់ ដាវីឌបានប្រុងប្រៀបខ្លួនរួចជាស្រេច ។





សូមសរសេរអំពើសំខាន់បំផុត ដែលដាវីឌបានធ្វើ ដើម្បីអោយគាត់មានចិត្តក្លាហាន ។ _____

ដាវីឌបានគ្រវែងចោលគ្រាប់ក្រួសមួយទៅ ។ ព្រះជាម្ចាស់ធ្វើឱ្យគ្រាប់ក្រួសនោះទៅចំគោលដៅ ។ មនុស្សមាឌយក្សក៏ដួលស្លាប់ទៅ ។



ដាវីឌក្លាហានដូចនេះ មកពី :

☐ គាត់ទុកចិត្តលើព្រះជាម្ចាស់ ។
☐ គាត់នៅក្មេង ។

ពួកភីលីស្ទីននាំគ្នារត់គេចទៅ ។ កងទ័ពអ៊ីស្រាអែលក៏ដេញតាម ។ ដាវីឌដណ្តើមបានជោគជ័យយ៉ាងធំជូនពួកអ៊ីស្រាអែល ។

© Project WorldReach © SEAN



ដាវីឌបានទទួលកិត្តិយសយ៉ាងធំ ដោយសារគាត់ទុកចិត្តលើព្រះ-បន្ទូលរបស់ព្រះជាម្ចាស់ ។ រឿងនេះមានចែងក្នុង ១ សាមូអែល ជំពូក ១៧ ។



ក្រោយមក ពេលដែលស្តេចសូលសុគតទៅ ព្រះជាម្ចាស់ក៏លើកដាវីឌជាស្តេច ។

ដោយសារតែស្តេចដាវីឌស្មោះត្រង់ ទើបព្រះជាម្ចាស់សន្យានឹងស្តេចដាវីឌថា កូនចៅទ្រង់នឹងគ្រប់គ្រងលើអ៊ីស្រាអែលជារៀងរហូត ។ សេចក្តីសន្យានេះបានសំរេច ដោយសារព្រះគ្រីស្តដែលជាមហាក្សត្រអស់កល្ប ។ ព្រះយេស៊ូជាព្រះញាតិវង្សរបស់ស្តេចដាវីឌ ។

